រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

008KH01A-01

មហាបណ្តាំ
បេសកកម្មសកលលោក



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៨

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ប្រើអ្នក ដើម្បីណែនាំប្រជា-រាស្ត្ររបស់ព្រះអង្គ ឱ្យចេញទៅផ្សព្វផ្សាយដំណឹងល្អ និងពង្រីកព្រះរាជ្យរបស់ព្រះអង្គ ។

នៅក្នុងម៉ាថាយ ២៨:១៨-២០ : ព្រះគ្រីស្តមានព្រះបន្ទូលពី «មហាបណ្តាំ» របស់ព្រះអង្គប្រាប់ដល់យើង ។

ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឱ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថៃ រហូតដល់អវសានកាលនៃពិភពលោក ។



- ស្រឡាញ់ព្រះជាម្ចាស់ និងមនុស្សឯទៀតៗ (ម៉ាថាយ ២២:៣៧-៣៩) ។
- អធិស្ឋាន និងសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ (ម៉ាថាយ ៤:៤, ៦:៥-១៣) ។
- ចែកចាយ និងថ្វាយដង្វាយ (ម៉ាថាយ ៦:១៩-២០)។
- ចូលរួមធ្វើពិធីកាច់នំប៉័ង និងការថ្វាយបង្គំ (លូកា ២២:១៧-២០) ។
- បង្កើតសាវ័ក គឺផ្សព្វផ្សាយដំណឹងល្អ និងបង្រៀនឱ្យគេប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានបង្គាប់ (ម៉ាថាយ ២៨:១៨-២០) ។

• អរគុណ និងលើកទឹកចិត្តពួកអ្នក ដែលព្យាយាមក្នុងការផ្សព្វផ្សាយដំណឹងល្អ ។

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនពួកអ្នកជឿដែលនៅក្នុងក្រុមជំនុំ ឬ ក្រុមរបស់អ្នក អំពីផ្នែកទាំងបីនៃមហាបណ្តាំរបស់ព្រះគ្រីស្ត នៅក្នុងម៉ាថាយ ២៨:១៨-២០ :
  - អំណាចរបស់ព្រះអង្គ ។
  - សេចក្តីបង្គាប់របស់ព្រះអង្គ ។
  - សេចក្តីសន្យារបស់ព្រះអង្គ ។
- ណែនាំប្រមូលពួកសមាជិករបស់ក្រុមជំនុំ ឬ ក្រុមរបស់អ្នក អោយផ្សព្វផ្សាយដំណឹងល្អប្រាប់មិត្តភក្តិ និងសាច់ញាតិ របស់ពួកគេផ្ទាល់ ហើយបង្រៀនអ្នកទាំងនោះអោយប្រតិបត្តិ តាមសេចក្តីគ្រប់យ៉ាង ដែលព្រះគ្រីស្តបានបង្គាប់ ។ ព្រះអង្គបង្គាប់សេចក្តីសំខាន់ប្រាំពីរយ៉ាង :
  - កែប្រែចិត្តគំនិត ហើយទទួលជឿ (ម៉ាកុស ១:១៥)។
  - ទទួលពិធីជ្រមុជទឹក (ម៉ាកុស ១៦:១៦) ។

មហាបណ្តាំនៅក្នុងម៉ាថាយ ២៨:១៨-២០ ទាក់ទងទៅនឹងរបៀប ដែលយើងត្រូវបង្កើតសាវ័កថ្វាយព្រះអម្ចាស់យេស៊ូគ្រីស្ត ។

មហាបណ្តាំមានបីផ្នែកគឺ :

- អំណាចរបស់ព្រះគ្រីស្ត ។
- សេចក្តីបង្គាប់របស់ព្រះគ្រីស្ត ។
- សេចក្តីសន្យារបស់ព្រះគ្រីស្ត ។

អំណាចរបស់ព្រះគ្រីស្ត

នៅក្នុងបទគម្ពីរនេះ ព្រះគ្រីស្តប្រកាសប្រាប់អំពីឫទ្ធានុភាពរបស់ ព្រះអង្គ :

«ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើ ផែនដី » ។ (ម៉ាថាយ ២៨:១៨)

យើងស្តាប់បង្គាប់ព្រះយេស៊ូគ្រីស្ត ពីព្រោះព្រះអង្គជា :

☐ អ្នកបញ្ជាដ៏ខ្ពង់ខ្ពស់បំផុត ។

☐ ទីប្រឹក្សាដែលអនុគ្រោះ ។

សេចក្តីបង្គាប់របស់ព្រះគ្រីស្ត

នៅក្នុងបទគម្ពីរនេះ ព្រះអម្ចាស់បង្គាប់ពួកសាវ័កថា÷

«ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាម សេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា » ។

(ម៉ាថាយ ២៨:១៩-២០)

មហាបណ្តាំគឺជា :

☐ សេចក្តីបង្គាប់ដែលពេញដោយឫទ្ធានុភាព ។

☐ សេចក្តីអញ្ជើញដែលទន់ខ្សោយ ។



© Project WorldReach © SEAN

ព្រះគ្រីស្តមានបន្ទូលអោយយើងចេញទៅបង្កើតសាវ័ក ដោយធ្វើពិធីជ្រមុជទឹកអោយពួកគេសិន ទើបបង្រៀនពួកគេអោយប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ ។ នៅក្នុងសម្ពន្ធមេត្រីថ្មី ពេលដែលគេថ្វាយខ្លួនហើយ គេតែងតែទទួលពិធីជ្រមុជទឹកទុកជាទីសំគាល់អំពីជំនឿថ្មីរបស់គេ ។

កំណត់ចំណាំ :

មនុស្សខ្លះបែរចេញពីព្រះជាម្ចាស់ ក្រោយពីបានទទួលពិធីជ្រមុជទឹកហើយ ។ បើគេបែរមកជឿលើព្រះអម្ចាស់វិញ តាមធម្មតាយើងមិនត្រូវធ្វើពិធីជ្រមុជទឹកអោយពួកគេម្តងទៀតទេ ។ សូមទទួលពួកគេជាសមាជិករបស់ក្រុមជំនុំវិញ តាមរបៀបរបបរបស់ក្រុមជំនុំរបស់អ្នកចុះ ។

សរសេរសេចក្តីដែលព្រះអម្ចាស់បង្គាប់ដល់យើង នៅក្នុងមហា-បណ្តាំ ដោយពាក្យសំដីអ្នកផ្ទាល់ :



សេចក្តីសន្យារបស់ព្រះគ្រីស្ត

ព្រះអម្ចាស់សន្យាថា ទ្រង់គង់នៅជាមួយសិស្សរបស់ព្រះអង្គជានិច្ច :

«ខ្ញុំនៅជាមួយអ្នករាល់គ្នា ជារៀងរាល់ថ្ងៃ រហូតដល់ អវសានកាលនៃពិភពលោក » ។



ព្រះអង្គសន្យាតាមរយៈខគម្ពីរទាំងអស់នេះថា នឹងធ្វើការអស្ចារ្យ ។ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គ :

☐ ទុកអោយយើងធ្វើកិច្ចការ ដែលព្រះអង្គបង្គាប់អោយធ្វើ ដោយខ្លួនឯងផ្ទាល់ ។

☐ គង់នៅជាមួយយើងជានិច្ច ។

មហាបណ្តាំនៅក្នុងម៉ាថាយ ២៨:១៨-២០ មានបីផ្នែកគឺ អំណាចរបស់ព្រះអម្ចាស់ សេចក្តីបង្គាប់ និងសេចក្តីសន្យារបស់ព្រះអង្គ :

១- ព្រះគ្រីស្តប្រកាសប្រាប់ពីអំណាចដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គ (ខ ១៨) ។

២- ព្រះគ្រីស្តបង្គាប់ឱ្យយើងចេញទៅបង្កើតសាវ័ក (ខ ១៩) ។

៣- ព្រះគ្រីស្តសន្យាថា នឹងគង់នៅជាមួយយើង (ខ ២០) ។

នេះជាសេចក្តីបង្គាប់ អោយយើងទៅប្រកាសអំពីព្រះសង្គ្រោះរបស់យើងប្រាប់ដល់មនុស្សទាំងឡាយ ។ ព្រះអង្គអោយយើងទៅផ្សព្វផ្សាយដំណឹងល្អ ដើម្បី :

☐ បង្កើតសាវ័ករបស់ព្រះគ្រីស្ត ។

☐ បង្ហាញថា យើងបរិសុទ្ធជាងពួកគេ ។

ព្រះយេស៊ូបង្គាប់យើងអោយទៅផ្សព្វផ្សាយដំណឹងល្អ ដើម្បីបង្កើតសាវ័ក ។ តើពិតមែន ឬ មិនពិត ?

☐ ពិតមែន ។

☐ មិនមែនទេ ។

នៅក្នុងម៉ាថាយ ២៨:១៨-២០ ព្រះអង្គបង្គាប់យើងអោយចេញទៅរកមនុស្ស ដែលគេមិនទាន់ផ្សាយដំណឹងល្អប្រាប់ ដើម្បីបង្កើតសាវ័ក ។ តើកិច្ចការពីរយ៉ាង ដែលយើងត្រូវធ្វើជាមួយពួកគេដើម្បីបង្កើតសាវ័ក គឺអ្វីខ្លះ ?

១- _____ ។

២- _____ ។

© Project WorldReach © SEAN

ព្រះគ្រីស្តជាព្រះអម្ចាស់លើជីវិតរបស់យើង

ព្រះអង្គបង្គាប់យើងអោយចេញទៅផ្សព្វផ្សាយដំណឹងល្អពាសពេញពិភពលោកទាំងមូល ។ ព្រះអង្គមិនបានប្រើពាក្យស្រាលៗ ដូចជាទីប្រឹក្សាទេ ។ ក៏ប៉ុន្តែ ព្រះអង្គប្រើពាក្យបញ្ជាម៉ឺងម៉ាត់ខ្លាំងៗវិញ ។ ព្រះអង្គមិនអង្វរយើងថា÷ «សូមចេញទៅ បើអ្នកចង់ទៅ...» ផ្ទុយទៅវិញ ព្រះអង្គមានបន្ទូលថា÷ «*ចូរចេញទៅបង្កើតសាវ័ក...!*» ។

នៅក្នុងមហាបណ្តាំ ព្រះគ្រីស្តមានព្រះបន្ទូលមកកាន់យើង ដោយប្រើពាក្យដូច :

☐ អ្នកជំនួយដែលទន់ភ្លន់ ។

☐ មេបញ្ជាការដែលខ្ពង់ខ្ពស់បំផុត ។

ព្រះគ្រីស្តជាព្រះអម្ចាស់របស់យើង ។ ព្រះអង្គចង់អោយយើងធ្វើតាមគ្រប់សេចក្តីបង្គាប់របស់ព្រះអង្គ ដោយសេចក្តីស្រឡាញ់ និងដោយគ្មានជជែកតវ៉ា ។ ព្រះអង្គមានព្រះបន្ទូលថា÷«*ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី*» ។ នេះហើយជាអំណាចពិតប្រាកដ !

តើព្រះគ្រីស្តពិតជាបង្គាប់ក្រុមជំនុំរបស់ព្រះអង្គអោយចេញទៅភូមិឆាយដាច់ស្រយាលបំផុត ប្រទេសដទៃ និងសង្កាត់ដែលនៅក្បែរយើង ដើម្បីបង្កើតសាវ័កឬ ?

☐ ពិតមែន ។

☐ មិនមែនទេ ។

តើអ្នកដែលទៅផ្សព្វផ្សាយដំណឹងល្អ ពីព្រះយេស៊ូគ្រីស្តប្រាប់ដល់អ្នកជិតខាងរបស់អ្នកដែរឬទេ ?

☐ ដែល ។

☐ មិនដែលទេ ។



គ្មានមេបញ្ជាការ ឬ អ្នកដឹកនាំណាដែលមានអំណាចលើសព្រះ-យេស៊ូទេ ។ ព្រះគ្រីស្តមានអំណាចគ្រប់យ៉ាង ។ ព្រះអង្គបង្គាប់យើង ដោយសារអំណាចនេះថា÷ *«ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេ .....ហើយត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា»* ។

សាវ័ករបស់ព្រះយេស៊ូ មិនមែនគ្រាន់តែ «ទទួល» ព្រះយេស៊ូតែប៉ុណ្ណោះទេ ។ ពួកគេក៏ត្រូវធ្វើតាមសេចក្តីបង្គាប់ទាំងអស់របស់ព្រះអង្គផងដែរ ។ សិស្សត្រូវធ្វើតាមគ្រូគ្រប់យ៉ាង ។ អ្នកដើរតាមព្រះយេស៊ូត្រូវទទួលពិធីជ្រមុជទឹក ហើយធ្វើតាមសេចក្តីគ្រប់យ៉ាងដែលព្រះអម្ចាស់បង្គាប់ ។

«ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះ-បិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថៃ រហូតដល់អវសានកាលនៃពិភពលោក » ។

នៅក្នុងម៉ាថាយ ២៨:១៨-២០ ព្រះអម្ចាស់មានបន្ទូលប្រាប់យើងអោយចេញទៅរកមនុស្សគ្រប់ជាតិសាសន៍ និងគ្រប់ប្រភេទ ។ ដូច្នេះ តើត្រូវរាប់បញ្ចូលទាំងមនុស្សដែលនៅក្នុងភូមិឆ្ងាយដាច់ស្រយាលរបស់ប្រទេសយើងដែរឬទេ ?

☐ ត្រូវរាប់បញ្ចូល ។

☐ មិនត្រូវរាប់ទេ ។

តើត្រូវរាប់បញ្ចូលមនុស្ស ដែលនៅក្នុងប្រទេសដទៃដែរឬទេ ?

☐ ត្រូវរាប់បញ្ចូល ។

☐ មិនត្រូវរាប់ទេ ។

តើត្រូវរាប់បញ្ចូលពួកអ្នកជិតខាង ដែលនៅក្បែរយើងដែរឬទេ ?

☐ ត្រូវរាប់បញ្ចូល ។

☐ មិនត្រូវរាប់ទេ ។

© Project WorldReach © SEAN